**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :......០៣៧/២៥..................**ក.ប**/ស.ឃ.ណ.អ.រ.ហ

# សេចក្តីជូនដំណឹង
## ស្តីពី
## ចលនាប្រឡងប្រណាំង «សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ» សម្រាប់ឆ្នាំ២០២៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ មេត្តាជ្រាបថា ក្រសួងនឹងដាក់ឱ្យដំណើរការចលនាប្រឡងប្រណាំង «សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ» សម្រាប់ឆ្នាំ២០២៦ ក្នុងគោលបំណងចូលរួមលើកកម្ពស់សុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ សំដៅបង្កើតនូវវប្បធម៌អនុលោមភាពការងារ ពង្រឹងប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទការងារនៅថ្នាក់សហគ្រាស ក្រុមហ៊ុន រោងចក្រ ពង្រឹងការអនុវត្តរបបសន្តិសុខសង្គម និងបង្កើនផលិតភាពការងារ។

ដើម្បីចូលរួមចលនាប្រឡងប្រណាំង «សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ» សម្រាប់ឆ្នាំ២០២៦ ក្រសួងសូមណែនាំដល់ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ ដូចខាងក្រោម៖

១. សូមដាក់ពាក្យស្នើសុំចូលរួមក្នុងប្រព័ន្ធ **SICMS** ដែលមានតំណភ្ជាប់ **https://sicms.mlvt.gov.kh/com/peaceful_register/**

២. កាលបរិច្ឆេទដាក់ពាក្យស្នើសុំចូលរួម៖ **ចាប់ពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ ដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៦។**

ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

- លោក គុន សំផន ទូរសព្ទលេខ ០១២ ៩២៤ ៦១៤
- លោក លាង សុភ័គ ទូរសព្ទលេខ ០៩៩ ៨៨៣ ៣៥៨

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ ដាក់ពាក្យចូលរួមប្រកួតប្រជែងចលនាប្រឡងប្រណាំង «សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ» សម្រាប់ឆ្នាំ២០២៦ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០២៥

**ចម្លងជូន៖**

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

  **"ដើម្បីមុខការអនុវត្ត និងផ្សព្វផ្សាយ"**

- ឯកសារ កាលប្បវត្តិ